ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២២៧

ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥

សាលដីកា

លេខ : ១៥៣

ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៦

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម | ឌិត មុន្ទី | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | វឿល មួន | ជាចៅក្រម |
| ៣-លោក | ឈឹម ស៊ីផល | ជាចៅក្រម |
| ៤-លោក | ប៉ែន សារឿន | ជាចៅក្រម |
| ៥-លោក | ម៉ុង មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៥២"ឈ" ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៤ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទ ឈ្មោះ វ៉ន គីមឡេង "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥០E០ ផ្លូវលេខ ១៣៦ ក្រុមទី៥ សង្កាត់ផ្សារថ្មីទី៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះ លីវ សុវណ្ណ ជាតំណាង ។

និងចុងចម្លើយឈ្មោះ ហ៊ួរ ម៉ាច "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៦១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ សង្កាត់បឹងកេងកង២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីឈ្មោះ ហេង សុធាវណ្ណរិទ្ធិ ជាតំណាង ។

**កម្មវត្ថុបណ្តឹង** : ប្តឹងជំទាស់នឹងការអនុវត្តសាលដីការដ្ឋប្បវេណីលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល

បានឃើញបណ្តឹងសាទុក្ខលេខ ១៣១ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះ ហួន ចិន្ទន មេធាវីតំណាងឱ្យឈ្មោះ វ៉ន គីមឡេង ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៥២"ឈ" ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍លើចំណុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ វ៉ែន គីមឡេង ប្តឹងសុំផ្អាកការអនុវត្តសាលដីការដ្ឋប្បវេណីលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ដោយអាងហេតុថា មានដីកាបង្គាប់លេខ ៣៩៨៤ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ជូនដំណឹងទៅលោក យឹម សំណោង ថានឹងចុះរឹបអូសផ្ទះលេខ ៣៩៥០ E₀AE₁+AE₂ ផ្លូវលេខ ២៨២ ក្រុម២៨ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន ដែលមានប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០០៦០០លប ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០០ ដោយមានអាជ្ញាធរសង្កាត់ដឹងលឺ តែពុំទាន់បានកាត់ឈ្មោះនៅឡើយ ។ ម្យ៉ាងទៀតខ្លួនបានកាន់កាប់ផ្ទះនេះតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ ។ នៅពេលខ្លួនដឹងថាមានការចុះរឹបអូសផ្ទះខាងលើ ខ្លួនបានដាក់ពាក្យបណ្តឹង នៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០៤ ដើម្បីចូលជាគតិយជនជំទាស់នឹងការអនុវត្តសាលដីការួចហើយ នៅតុលាការក្រុងភំពេញ ។ ខ្លួនសំណូមពរសុំឱ្យផ្អាកការអនុវត្តសាលដីការបស់តុលាការកំពូលខាងលើសិន ដើម្បីរង់ចាំតុលាការសម្រេចលើបណ្តឹងជំទាស់របស់ខ្លួនក្នុងរឿងអង្គសេចក្តីចប់សិន ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ ០៥ ប្រក ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យផ្ទេរសិទ្ធិពីលោក វ៉ែន គីមឡេង ឱ្យលោកស្រី សេង សុខុម និងពាក្យសុំការពារក្តីរបស់មេធាវី លីវ សុវណ្ណា ឱ្យដើមចោទ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ទទួលពាក្យសុំតំណាង និងការពារក្តីរបស់មេធាវី ហេង សុធាវណ្ណារិទ្ធ និងចម្លើយការពារ និងប្តឹងសុំនៅពេលសវនាការឱ្យចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-បដិសេធពាក្យប្តឹងទាស់ជាបន្ទាន់ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ និងចម្លើយលោកស្រី សេង សុខុម និងមេធាវី លីវ សុវណ្ណា តំណាងឱ្យលោក វ៉ែន គីមឡេង ចោល ។

៤-ឱ្យលោកព្រះរាជអាជ្ញាជាអ្នកអនុវត្តសាលក្រម អនុវត្តបន្តនូវសាលដីការដ្ឋប្បវេណីលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល តាមច្បាប់ស្តីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី ៤.០០០រៀល ដែលបានកាត់យកពីប្រាក់ប្រដាប់ក្តីរបស់ដើមចោទដាក់ថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ ។

៦-ដីកាសម្រេចនេះ ជំនុំជំរះ កាលពីថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៥ ហើយលើកណាត់គូភាគី និងមេធាវី មកប្រកាសនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៥ វេលាពេលព្រឹក ចំពោះមុខមេធាវីនៃគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

៧-ដីកាសម្រេចនេះ មានអានុភាពអនុវត្តភ្លាម ទោះជាប់ក្នុងបណ្ដឹងឧទ្ធរណ៍ក៏ដោយ ( មាត្រា ៧៦ នៃច្បាប់ស្ដីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី) ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ សេង សុខុម ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៥ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃដីកាទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៥២"ឈ" ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៥ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៥ របស់ឈ្មោះ សេង សុខុម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ ០៥ប្រក ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១១ ខែមេសា ឆ្នាំ២០០៥ ចំពោះមុខមេធាវីតំណាងគូក្ដី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៥ ចំពោះមុខមេធាវីតំណាងគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៣១ ចុះថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះ ហួន ចិន្ដុន មេធាវីតំណាងឱ្យឈ្មោះវ៉ិន គឹមឡេង ស្ថិតនៅក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះ ហួន ចិន្ដុន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញ សារណាតបរបស់ឈ្មោះ ហួរ ម៉ាច ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

បានស្ដាប់របាយការណ៍របស់ ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ថា :

-បណ្ដឹងសាទុក្ខរបស់មេធាវីតំណាងដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

-ផ្អាកការអនុវត្តសាលដីការដ្ឋប្បវេណីស្ថាពរលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ហួរ ម៉ាច ។

មេធាវីរបស់ដើមចោទ ធ្វើសេចក្ដីសន្និដ្ឋានថា :

-កូនក្តីខ្លួនបានស្នាក់នៅ និងកាន់កាប់ផ្ទះនេះតាំងពីឆ្នាំ២០០០ ដោយមានកិច្ចសន្យាទិញលក់ មុនដីកាកិច្ចការប្រញាប់របស់តុលាការ ហើយការទិញលក់នេះ មានការទទួលស្គាល់ពីរដ្ឋអំណាចទៀត ។ ខ្លួនសុំឱ្យកូនក្តីខ្លួនបានចូលជាតតិយជន រង់ចាំតុលាការអង្គសេចក្តីសម្រេចសិន ។

មេធាវីរបស់ចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថា :

-កូនក្តីខ្លួនមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ហើយសាលដីការបស់តុលាការកំពូលសម្រេចរឹបអូសផ្ទះនេះដើម្បីធានាសំណង ។ នៅពេលតុលាការចេញដីកាកិច្ចការប្រញាប់ឃាត់ផ្ទះនេះ ដើមចោទពុំបានសុំចូលជាតតិយជនទេ ទាល់តែគេចុះអនុវត្តសាលដីការបស់តុលាការកំពូលទើបសុំចូលជាតតិយជន ។ ដើមចោទគ្មានសិទ្ធិអ្វីមកប្តឹងជំទាស់ការអនុវត្តនេះទេ ព្រោះគាត់មិនមែនជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនេះទេ ។

-ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ សារណារបស់ចុងចម្លើយ និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៣១ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០៥ របស់លោកមេធាវីដើមចោទធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាម មាត្រា ១៤ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការទាមទារសិទ្ធិនៃកម្មសិទ្ធិលើផ្ទះលេខ ៣៩$AE_0$, $AE_1$, $AE_2$ តុលាការក្រុងភ្នំពេញ កំពុងចាត់ការជារឿងអង្គសេចក្តី ហើយតុលាការពុំទាន់សម្រេចថា កម្មសិទ្ធិករ នៃផ្ទះនេះជាអ្នកណានៅឡើយទេ ដែលគប្បីតុលាការកំពូលបង្អង់ការរឹបអូសផ្ទះខាងលើ ដែលជាការអនុវត្តសាលដីការដ្ឋប្បវេណីលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ជាបណ្តោះអាសន្នមួយរយៈសិន រង់ចាំការសម្រេចអង្គសេចក្តីចូលជាស្ថាពរ ។

-យល់ឃើញថា គូភាគីនៃរឿងក្តីនេះ ពុំបានមកចូលរួមសវនាការនេះ តាមការកោះអញ្ជើញទេ ប៉ុន្តែមេធាវីរបស់គូភាគីបានមកចូលរួមសវនាការនេះហើយ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះ ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តី កំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-បង្គង់ការរឹបអូសដើម្បីលក់ឡាយឡុង ផ្ទះលេខ ៣៩AE... AE1និង AE2 ដែលជាការអនុវត្តសាលដីការដ្ឋប្បវេណីលេខ ១៧៥ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ជាបណ្តោះអាសន្ន រហូតដល់រឿងនៃអង្គសេចក្តី ស្តីពីសិទ្ធិជាម្ចាស់លើផ្ទះនេះត្រូវបានតុលាការសម្រេចជាស្ថាពរ ។

២-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២២៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលទៅក្នុងសំណុំរឿងអង្គសេចក្តីខាងលើ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលភាគីដើមចោទឈ្មោះ វីន គឹមឡេង បានបង់ទុកនៅតុលាការកំពូល គឺ :

.ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

.ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤-សាលដីកានេះ ប្រកាសទាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៦ ។